# មេរៀនទី២
# ទម្រង់អាជីវកម្ម

# ទម្រង់អាជីវកម្ម

- ទម្រង់ស្របច្បាប់របស់អង្គភាពអាជីវកម្ម
- កម្មសិទ្ធបញ្ញា
- ច្បាប់ការងារ

# ទម្រង់ស្របច្បាប់របស់អង្គភាពអាជីវកម្ម

- សហគ្រាសឯកបុគ្គល
- ក្រុមហ៊ុនសហកម្មសិទ្ធិ
- ក្រុមហ៊ុនមូលធន

# សហគ្រាសឯកបុគ្គល

- សហគ្រាសដែលបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។
- ប្តី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវចាត់ទុកថាជារូបវន្តបុគ្គលតែម្នាក់។

# គុណសម្បត្តិនៃសហគ្រាសឯកបុគ្គល

- ងាយស្រួលក្នុងការបង្កើត
- ភាពជាម្ចាស់ទោលចំពោះប្រាក់ចំណេញ
- ការធ្វើសេចក្ដីសម្រេចចិត្តនិងត្រួតពិនិត្យដោយម្ចាស់ម្នាក់
- ភាពបត់បែនបាន
- សេរីភាពពីការកំណត់ពន្ធលើអាជីវកម្មរួម
- ងាយស្រួលចាកចេញពីអាជីវកម្មបើសិនចាំបាច់
- ការចំណាយដំណាក់កាលចាប់ផ្ដើមទាប

# គុណវិបត្តិនៃសហគ្រាសឯកបុគ្គល

- ការទទួលខុសត្រូវចំពោះបំណុលមិនកំណត់ដែលជាបញ្ហាធំបំផុតសម្រាប់អាជីវកម្មបែបនេះ
- ខ្វះនិរន្តភាព
- បញ្ហាក្នុងការស្វែងរកឬបង្កើតមូលធន
- ទាក់ទងនឹងទស្សនៈនិងបទពិសោធន៍មានកំណត់
- មានការទទួលខុសត្រូវទាំងស្រុងលើអាជីវកម្ម

# ការបញ្ចប់សហគ្រាសឯកបុគ្គល

- ដោយស្ម័គ្រចិត្ត
  - ផ្ទេរសិទ្ធិឬលក់ភាគហ៊ុនទៅឱ្យបុគ្គលផ្សេងទៀត
  - តាមកាលកំណត់របស់ច្បាប់។
- ដោយមិនស្ម័គ្រចិត្ត។
  - កម្មសិទ្ធិករទទួលមរណៈភាព
  - បញ្ចប់តាមផ្លូវតុលាការ ឬ
  - នៅពេលដែលសហគ្រាសក្ស័យធន។

# ក្រុមហ៊ុនសហកម្មសិទ្ធិ

- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ
- ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

# ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ-និយមន័យ

- ក្រុមហ៊ុនសហកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងបុគ្គល២ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ ហើយសមាជិកទាំងអស់ជាសហកម្មសិទ្ធិករទូទៅ។

# គុណសម្បត្តិនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- ងាយក្នុងការបង្កើត
- ប្រមូលផ្តុំភាពប៉ិនប្រសព្វ
- ប្រមូលផ្តុំនូវធនធាន
- មានភាពងាយស្រួលក្នុងការរកហិរញ្ញប្បទាន
- ភាពបត់បែន
- អាចទទួលបានអត្ថប្រយោជន៍ពន្ធ

# គុណវិបត្តិនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- ទទួលខុសត្រូវចំពោះបំណុលមិនកំណត់
- ការសម្រេចចិត្តនិងសិទ្ធិអំណាចត្រូវបានបែងចែក
- សក្តានុពលសម្រាប់ការខ្វែងគំនិត
- អាចបន្តនៃការផ្ទេរភាពជាកម្មសិទ្ធិ

# ការបញ្ចប់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការត្រួតពិនិត្យអង្កេតពេលក្ស័យធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬបញ្ជាឱ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ។

# ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត-និយមន័យ

- ក្រុមហ៊ុនសហសកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើននាក់ទៀត ដែលមានកាតព្វកិច្ចបង់ភាគទុកចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។

# គុណសម្បត្តិនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

- វិធីដ៏ល្អដើម្បីទិញយកមូលធនពីដៃគូមានកម្រិត

# គុណវិបត្តិនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

- ការចំណាយ និងភាពស្មុគស្មាញនៃការបង្កើតខ្ពស់
- ដៃគូមានកម្រិតមិនអាចចូលរួមក្នុងការគ្រប់គ្រងអាជីវកម្មបាន

# ការបញ្ចប់នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

- សហកម្មសិទ្ធិករទូទៅមិនអាចបន្តទៀត និងជំនួសដោយសហកម្មសិទ្ធិករមានកម្រិត១២០ ថ្ងៃ ផ្ដែករង្គបាល ។ គ្មានសហកម្មសិទ្ធិករទូទៅជំនួស១២០ថ្ងៃទេក្រុមហ៊ុនត្រូវបានបញ្ចប់។
- កាលមកដល់វេលាកំណត់៩៩ឆ្នាំ មិនបន្តទៀត។
- ជម្រះបញ្ជីតាមផ្លូវតុលាការក្នុងករណីក្ស័យធន
- ដោយតុលាការ ការបំពានកម្មវត្ថុអាជីវកម្ម ។
- សហកម្មសិទ្ធិករទូទៅណាម្នាក់ទទួលមរណៈភាព ។

# ក្រុមហ៊ុនមូលធន

- ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតដោយលក្ខន្តិកៈនិងជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់ភាគហ៊ុន ហើយម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមចំនួនភាគហ៊ុនដែលខ្លួនបានទិញ។ ក្រុមហ៊ុននេះគ្រប់គ្រងនិងដឹកនាំដោយក្រុមប្រឹក្សាភិបាល។

# ក្រុមហ៊ុនមូលធន

- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

# ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត-និយមន័យ

- ក្រុមហ៊ុនមូលធនមួយប្រភេទដែលបង្កើតឡើងនិងចុះបញ្ជីតាមច្បាប់ មានសមាជិកភាគហ៊ុនចាប់ពី២នាក់រហូតដល់៣០នាក់ ហើយសមាជិក ម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុន ត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនបានដាក់ដើមទុនក្នុងក្រុមហ៊ុន ប៉ុណ្ណោះ នឹងមិនអាចលក់ភាគហ៊ុនជាសាធារណៈបាន។

# គុណសម្បត្តិនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

- ទទួលខុសត្រូវលើបំណុលមានកំណត់
- កម្មសិទ្ធិអាចផ្ទេរបាន
- មានភាពបន្តក្នុងករណីប្រធានសក្តិ
- ងាយប្រមូលធនធាន

# គុណវិបត្តិនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

- ចំណាយច្រើនដើម្បីបង្កើត
- ការបង់ពន្ធទ្វេរ ពន្ធអាជីវកម្ម ពន្ធលើផលចំណេញ ពន្ធលើផលចំណូលរបស់បុគ្គល
- ខ្វះការសម្ងាត់

# ការបញ្ចប់នៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

- ម្ចាស់ភាគទុនព្រមព្រៀងគ្នា តាមសេចក្តីសម្រេចចិត្ត ដោយគ្មានបំណុល
- ការផុតរយៈពេលតាមច្បាប់កំណត់
- ក្ស័យធន
- កម្មវត្ថុអាជីវកម្មខុសច្បាប់

# ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត-និយមន័យ

- ក្រុមហ៊ុនមូលធនមួយប្រភេទបង្កើតឡើងនិងចុះបញ្ជីតាមច្បាប់ ដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដែលក្នុងនោះមានសមាសភាពជាអភិបាលយ៉ាងតិច៣រូប។ ក្រុមហ៊ុនប្រភេទនេះមានសិទ្ធិបោះចេញនូវមូលបត្រសម្រាប់លក់ជាសាធារណៈ។ ម្ចាស់ភាគហ៊ុនម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនមានក្នុងក្រុមហ៊ុនប៉ុណ្ណោះ។

# គុណសម្បត្តិនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

- ដូចគ្នានឹងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

# គុណវិបត្តិនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

- ចុះសោហ៊ុយក្នុងការបង្កើត
- មានការដាក់កំហិតដោយច្បាប់តឹងតែង
- ការបង់ពន្ធដារត្រួតគ្នា
- មានរចនាសម្ព័ន្ធស្មុកស្មាញ
- ខ្វះភាពសម្ងាត់

# ការបញ្ចប់នៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

- ម្ចាស់ភាគទុនព្រមព្រៀងគ្នា តាមសេចក្តីសម្រេចចិត្ត ដោយគ្មានបំណុល
- ការផុតរយៈពេលតាមច្បាប់កំណត់
- ក្ស័យធន
- ការចាត់ទុកជាមោឃៈនូវកិច្ចសន្យា
- មហាសន្និបាតរំលាយមុនផុតកំណត់
- ខាតបង់៣/៤ នៃដើមទុនអភិបាលត្រូវកោះប្រជុំរំលាយក្រុមហ៊ុន។

# កម្មសិទ្ធបញ្ញា

- និយមន័យ
- ប្រភេទផ្សេងៗនៃកម្មសិទ្ធិបញ្ញា

# កម្មសិទ្ធបញ្ញា-និយមន័យ

- ការបង្កើតសហគ្រាសមួយ=បង្កើតកម្មសិទ្ធបញ្ញា
- ជាការបង្កើតដោយគំនិតបញ្ញា ដូចជា តក្កកម្ម ស្នាដៃអក្សរសាស្រ្តនិងសិល្បៈ និមិត្តសញ្ញា រូបភាព និង គំនូរ ដែលត្រូវបានប្រើប្រាស់នៅក្នុង ពាណិជ្ជកម្ម។

# កម្មសិទ្ធបញ្ញា-សារៈសំខាន់

- បង្ការគូប្រកួតប្រជែងពីការចម្លង ឬធ្វើត្រាប់តាមផលិតផលរបស់ខ្លួន
- ជៀសវាងលើការចំណាយថវិកាខ្ជះខ្ជាយលើការស្រាវជ្រាវ និងកា
- ផ្សព្វផ្សាយនៅទីផ្សារ
- បង្កើតអត្តសញ្ញាណសហគ្រាសតាមរយៈម៉ាក
- ក្នុងការផ្តល់អាជ្ញាបណ្ណ ឬការផ្ទេរសិទ្ធិ ផ្សេងៗនៃកម្មសិទ្ធិបញ្ញា
- បង្កើតតម្លៃទីផ្សាររបស់ខ្លួន
- ទទួលបានមូលធន និងហិរញ្ញប្បទាន
- អាចពង្រីកទៅកាន់ទីផ្សារថ្មីៗ។

# ប្រភេទផ្សេងៗនៃកម្មសិទ្ធបញ្ញា

- កម្មសិទ្ធិឧស្សាហកម្ម
- សិទ្ធិអ្នកនិពន្ធ និង
- សិទ្ធិប្រហាក់ប្រហែល

# ប្រភេទផ្សេងៗនៃកម្មសិទ្ធបញ្ញា

- កម្មសិទ្ធិឧស្សាហកម្ម
- សិទ្ធិអ្នកនិពន្ធ និង
- សិទ្ធិប្រហាក់ប្រហែល

# កម្មសិទ្ធបញ្ញាសម្រាប់សហគ្រិន

- សិទ្ធិអ្នកនិពន្ធ( copyright )
- ពាណិជ្ជនាម( trade mark )
- ប្រកាសនីយបត្រតក្កកម្ម( patent )
- ការសម្ងាត់ពាណិជ្ជកម្ម ( trade secret )

# ច្បាប់ការងារ

- រដ្ឋធម្មនុញ្ញ
- ច្បាប់ស្តីពីការងារ
- បទបញ្ញត្តិទាំងឡាយរបស់រាជរដ្ឋាភិបាលនិងរបស់ក្រសួងទទួលបន្ទុក
- បទដ្ឋានការងារអន្តរជាតិ